# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១

### អូស្ត្រាលីនិងកម្ពុជា ពិភាក្សាអំពីច្បាប់ថ្មីស្តីពីពិការភាព

ថ្ងៃនេះ លោកបណ្ឌិត **Ben Gauntlett** ស្នងការទទួលបន្ទុកប្រឆាំងការរើសអើងជនមានពិការភាព និងលោក **Luke Arnold** ភារធារីស្ថានទូតអូស្ត្រាលី បានដឹកនាំកិច្ចសន្ទនា លើការរៀបចំច្បាប់ថ្មីស្តីពីពិការភាពនៃប្រទេសកម្ពុជា ជាមួយ ឯកឧត្តម **ឯម ច័ន្ទមករា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSVY) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)។

នៅក្នុងកិច្ចប្រជុំ លោកបណ្ឌិត Ben Gauntlett បានចែករំលែកបទពិសោធន៍របស់ប្រទេសអូស្ត្រាលី លើការរៀបចំនិងការអនុវត្តច្បាប់បរិយាបន្នពិការភាព។ ឯកឧត្តម ឯម ច័ន្ទមករា និងលោកបណ្ឌិត Ben Gauntlett ក៏បានពិភាក្សាគ្នាលើបទពិសោធន៍របស់ប្រទេសអូស្ត្រាលី ក្នុងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD)។

លោក Arnold បានមានប្រសាសន៍ថា "កិច្ចប្រជុំថ្ងៃនេះ គឺជាឱកាសដ៏មានសារៈប្រយោជន៍សម្រាប់អូស្ត្រាលី និងកម្ពុជា ដើម្បីចូលរួមចំណែកក្នុងន័យស្ថាបនាលើកិច្ចការដ៏សំខាន់ទាក់ទងនឹងសិទ្ធិមនុស្ស។ ទន្ទឹមនឹងការគាំទ្រជាយូរមកហើយ របស់កម្មវិធីកិច្ចសហប្រតិបត្តិការអូស្ត្រាលីសម្រាប់ជនមានពិការភាពនៅកម្ពុជា ខ្ញុំយល់ឃើញថា កិច្ចសន្ទនានេះ គឺជាជំនួបលើកដំបូងដែលមិនធ្លាប់មានពីមុនមក។"

លោក Arnold បានបន្តទៀតថា "ខ្ញុំសង្ឃឹមថាកិច្ចសន្ទនានេះ នឹងនាំទៅរកកិច្ចសហការជាបន្តទៀត រវាងគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី (AHRC) និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបានគោលដៅរួមគ្នារបស់យើងក្នុងការលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាព អនុលោមតាម UNCRPD។"

លោកបណ្ឌិត Ben Gauntlett បានមានប្រសាសន៍ថា គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី (AHRC) រីករាយស្វាគមន៍ចំពោះឱកាសនៃការចែករំលែកបទពិសោធន៍របស់អូស្ត្រាលីនេះ ក្នុងកិច្ចការការពារ និងលើកកម្ពស់សិទ្ធិជនពិការភាព។

លោកបណ្ឌិត Ben Gauntlett បានបន្តទៀតថា "ខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ចំពោះការប្តេជ្ញាចិត្តរបស់ខ្លួនលើកិច្ចគាំពារសិទ្ធិមនុស្សដ៏សំខាន់នេះ និងចំពោះការបោះជំហានដ៏សំខាន់នៅក្នុងការធ្វើកំណែទម្រង់ច្បាប់ស្តីពីសិទ្ធិជនមានពិការភាព។ ខ្ញុំសង្ឃឹមថា ការសន្ទនាថ្ងៃនេះនឹងក្លាយជាការចាប់ផ្តើមនៃទំនាក់ទំនងដ៏យូរអង្វែង រវាងអូស្ត្រាលីនិងកម្ពុជា ខណៈពេលដែលយើងបាននឹងកំពុងធ្វើកិច្ចការដ៏សំខាន់ដើម្បីលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាពនៅក្នុងប្រទេសរបស់យើងរៀងៗខ្លួន និងនៅក្នុងតំបន់។"

កិច្ចសន្ទនានេះបានធ្វើឡើងក្នុងបរិបទដែលប្រទេសកម្ពុជាបាន និងកំពុងបង្កើតច្បាប់ថ្មីមួយស្តីពីពិការភាព ដើម្បីអនុលោមតាមកាតព្វកិច្ចនានាក្រោមក្របខណ្ឌនៃUNCRPD។ មុនកិច្ចប្រជុំនេះ ស្ថានទូតអូស្ត្រាលី និង AHRC បានផ្តល់អនុសាសន៍ជាលក្ខណៈបច្ចេកទេសដល់ DAC អំពីការគិតគូរលើការបញ្ចូលនូវវិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋាន ទៅក្នុងច្បាប់ថ្មីស្តីពីពិការភាពនេះ។

លោកបណ្ឌិត Ben Gauntlett និងឯកឧត្តម ឯម ច័ន្ទមករា ក៏បានពិភាក្សានូវវិធីផ្សេងៗ ដើម្បីបន្តការសហការជាមួយគ្នាក្នុងការជំរុញការងារបរិយាបន្នពិការភាព និងការងារសិទ្ធិមនុស្សជាទូទៅ នៅក្នុងប្រទេសកម្ពុជា។

លោក Arnold បានមានប្រសាសន៍ថា "ខ្ញុំមានមោទនភាពដែលយើងបន្តកសាងកិច្ចសហការដែលមានជាងមួយទសវត្សរ៍មកហើយ រវាងរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាព និងការធានាឱ្យមានការចូលរួមរបស់ពួកគេដោយពេញលេញ នៅក្នុងសង្គមកម្ពុជា។"

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au